**BMI0057**

# សម្ភាសន៍ជាមួយឈ្មោះ ចាន់ ស៊ីថា ភេទស្រី អាយុ៤៤ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ កុមារ

## មុខងារបច្ចុប្បន្នៈ លក់ដូរ

## ស្រុកកំណើតនៅភូមិព្រៃស្វាយ ឃុំព្រៃស្វាយ ស្រុកមោងឫស្សី ខេត្តបាត់ដំបង

## សព្វថ្ងៃរស់នៅភូមិវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ហ៊ិន សុផានី

## ២៥:២៥ និង ២៩:៥៧

## ២០ទំព័រ

ផានី ៖ ថ្ងៃនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ។ ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ចង់សាកសួរមីងពីប្រវត្តិរបស់មីងដែលមីងឆ្លងកាត់ ម៉េចបានមីងមកដល់ស្រុកម៉ាឡៃនេះ ។ រឿងរ៉ាវមីងប្រាប់ទាំងប៉ុន្មាន ខ្ញុំសុំអនុញ្ញាតិយកទៅធ្វើជាសៀវភៅក៏ដូចជាសម្រាប់ក្មេងដើម្បីអ្នកស្រាវជ្រាវផ្សេងៗយកមកសិក្សារៀនសូត្រ ។

ស៊ីថា ៖ ចា៎!

ផានី ៖ ខ្ញុំអាចសុំថតជាសម្លេងក៏ដូចជាថតជារូបបានទេ?

ស៊ីថា ៖ មានអីទេ ។

ផានី ៖ មីងឈ្មោះអីគេ?

ស៊ីថា ៖ ឈ្មោះ ចាន់ ស៊ីថា ។

ផានី ៖ មានឈ្មោះក្រៅទេ?

ស៊ីថា ៖ មានឈ្មោះក្រៅ គេហៅរាល់ថ្ងៃឈ្មោះ នាង ។

ផានី ៖ អាយុប៉ុន្មានហើយ?

ស៊ីថា ៖ ៤៤ឆ្នាំ ។

ផានី ៖ ស្រុកកំណើតនៅណាដែរ?

ស៊ីថា ៖ ស្រុកកំណើតនៅស្រុកមោង ខេត្តបាត់ដំបង ។

ផានី ៖ នៅភូមិឃុំអី?

ស៊ីថា ៖ នៅភូមិព្រៃស្វាយ ឃុំព្រៃស្វាយ ។

ធានី ៖ មីងរស់នៅណារាល់ថ្ងៃ?

ស៊ីថា ៖ ស្រុកម៉ាឡៃ ។

ធានី ៖ នៅភូមិឃុំអីដែរ?

ស៊ីថា ៖ ភូមិវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ឪពុកមីងឈ្មោះអី?

ស៊ីថា ៖ ចាន់ ថុក ។

ធានី ៖ ម្ដាយ?

ស៊ីថា ៖ វ៉ាន់ ប៊ិន ។

ធានី ៖ គាត់អាយុប៉ុន្មាន?

ស៊ីថា ៖ ៦៤ ។

ធានី ៖ ដល់ពេលឪពុកអត់ដឹងស្លាប់ឬរស់?

ស៊ីថា ៖ ស្លាប់បាត់ហើយ សម័យវត់យួននោះ ។

ធានី ៖ មានបងប្អូនប៉ុន្មាននាក់?

ស៊ីថា ៖ មានបងប្អូន៤នាក់ ស្រី២ប្រុស២ ស្លាប់អាបីទៅនឹងស្លាប់មួយ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ប្អូន ៖ ស្រី២ ប្រុស៣ ។

ស៊ីថា ៖ ស្លាប់៧/៩ ។

ធានី ៖ កាលនឹងស្លាប់អាយុប៉ុន្មាន?

ស៊ីថា ៖ ៨ខែ ។

ធានី ៖ មុនក្រោយឲ្យតែបងប្អូន?

ស៊ីថា ៖ បងប្អូនទាំងអស់ឲ្យតែស្លាប់ក៏យកដែរ ។

ធានី ៖ ចា៎! ទាំងអស់គ្នាប៉ុន្មាននាក់?

ស៊ីថា ៖ បងមួយទៀត ។

ធានី ៖ បងប្អូនប៉ុន្មាននាក់ ៦?

ស៊ីថា ៖ ៦ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ស៊ីថា ៖ ប្រុស៤ ស្រី២ ។

ធានី ៖ ស្លាប់១ពេលវត់?

ស៊ីថា ៖ ស្លាប់កាលពីដើមមួយ មុនខ្មែរក្រហមមួយ ពេល៧៩មួយ ។

ធានី ៖ មុនខ្មែរក្រហមម៉េចបានស្លាប់?

ស៊ីថា ៖ ឈឺ ។

ធានី ៖ កូនបងគេ ឬម៉េច?

ស៊ីថា ៖ បងគេ បងខ្ញុំទៀត ។

ធានី ៖ បងកូនទីប៉ុន្មាន?

ស៊ីថា ៖ ទី២ ។

ប្អូន ៖ ស្លាប់បង ស្លាប់ពៅ ។

ធានី ៖ បងអាចជួយរៀបរាប់ពីដំបូង បងនៅពីស្រុកកំណើតមករហូតបានបងមកដល់នេះ?

ស៊ីថា ៖ នៅតាំងពី៧៩ យើងមកដល់?

ធានី ៖ អត់ទេ ដំបូងបងថាបងនៅស្រុកកំណើត ចង់ឲ្យបងរៀបរាប់ពីនៅស្រុកកំណើតដំបូងមកម៉េចបានមកដល់នេះ ។ មុនដំបូងបងថានៅបាត់ដំបង?

ស៊ីថា ៖ ចា៎!

ធានី ៖ និយាយពីពេលនឹងមក?

ស៊ីថា ៖ ចេញមកតាំងពីយូរដែរ ចេញមកតាំងពី៧៩ ។

ធានី ៖ មុន៧៩បងធ្វើអី?

ស៊ីថា ៖ មុន៧៩សម័យប៉ុលពតនឹង គិតពីនាំគ្នារត់ហ្នឹងហើយ ផុតពីរត់នឹងមក ។

ប្អូន ៖ មុន៧៩នឹង ប៉ាគាត់ធ្វើពេទ្យ១សម័យនឹង បើម្ដាយវិញធម្មតា ហើយបងស្រីខ្ញុំនៅកងកុមារ ហើយដូចខ្ញុំ បងប្រុសបន្ទាប់គាត់ ហើយនឹងខ្ញុំនៅកងកុមារដែរ ។

ធានី ៖ គាត់ធ្វើពេទ្យអីគេ?

ស៊ីថា ៖ ពេទ្យព្យាបាល ពេទ្យស្រុកមោង ។

ប្អូន ៖ បន្ទាប់ពីនឹងមក យួនក៏ចូលមក យើងល្បីថាអារ-កក៏រត់២០-៣០រទេះ ចេះរត់បណ្ដើរៗ ។ យួនតាមទាន់យួនក៏បាញ់ ខ្ញុំ៤នាក់បងប្អូនរត់ឡើងលើភ្នំ តែអ្នកនៅកន្លែងបាញ់នឹង គឺយួនចាប់បានទាំងអស់ ។ បន្ទាប់មក ៤នាក់បងប្អូនក៏ឡើងលើភ្នំតាមគេតាមឯងរយៈ៦ខែ អត់បាយអត់ទឹក ហូបតែស្លឹកឈើអង្ករម៉ាគ្រាប់ៗទេ ។ បានរយៈតែ៦ខែនឹង ហើយបានវិលមកជួបម្ដាយវិញស្រុកមោង ។ ម្ដាយយួនចាប់បាន គេបញ្ជូនមកស្រុកមោងដដែល ។ តែបន្ទាប់ពីជួបម្ដាយរួច បងប្អូនខ្ញុំសួរម្ដាយនៅវិញ ថាមូលហេតុអីបាត់ប៉ា ។ ប៉ារបស់ខ្ញុំបាត់តាំងពីសម័យយួនចាប់នឹងមក ដែលខ្ញុំរត់បែកគ្នានឹងមកបាត់ដល់សព្វថ្ងៃ ។

ធានី ៖ អត់ដឹងទៅណា?

ប្អូន ៖ ហើយបន្ទាប់មកក្រុមគ្រួសាររបស់ខ្ញុំក៏អង្ករអត់មានអីហូប ដើរបូតអង្ករក្នុងមួយថ្ងៃបាន៣កំប៉ុង មកបុកជាអង្ករបានកន្លះកំប៉ុង មកផ្សំជាមួយត្រួយរនោង ត្រួយស្លឹកល្ពៅ បបរឲ្យកូនហូប ។ ដល់ពេលអត់ពេកក៏ម្ដាយខ្ញុំនេះ ក៏សួរប្អូនប្រុសគាត់ថាអាចនាំគាត់មករស់នៅជាយដែនបានអត់ បានអង្កររបបហូបនឹងគេ ។ ប្អូនប្រុសគាត់នាំមកតាមដល់ជាយដែននឹង ។

ធានី ៖ ប្អូនប្រុសគាត់ធ្វើអីគេ បាននាំគាត់មកដល់?

ប្អូន ៖ ប្អូនប្រុសគាត់សម័យនឹងអត់ធ្វើអីផង ប្រជាជន ។

ស៊ីថា ៖ គាត់មកតាមអូរជ្រៅ គាត់ទិញអង្ករឲ្យហូបនៅបាត់ដំបង ។

ធានី ៖ ម៉េចបានគាត់អាចចេញចូល?

ប្អូន ៖ ចុះកាលសម័យនឹងយើងល្បីអ្នកណាអត់ គាត់ដឹងគាត់ចេញចូលរកស៊ីរត់ពន្ធ ។ ហើយចុង៧៩ ដើម៨០គត់ យើងល្បីថាបើយើងរត់មកដល់ជាយដែន អង្គការសហប្រជាជាតិចែកអង្ករឲ្យហូប ត្រីសាច់ យើងមិនបាច់ភ័យព្រួយបារម្ភ ។ យើងបែកសម័យ៧៩ យើងស្អីក៏អត់ដែរ ដីស្រូវអង្ករក៏អត់មាន ។

ធានី ៖ ម៉េចទៀត?

ប្អូន ៖ ហើយបន្ទាប់មក ពូនឹងគាត់នាំមកដល់ហៅជំរុំថ្មីខេត្តបន្ទាយមានជ័យ ខាងដើងប៉ោយប៉ែតនឹង ។ ចុង៧៩ ដើម៨០គត់ ។ ៨០គត់យើងនៅប៉ារ៉ាខ្មែរក្រហមប្រឫកប្រចល់គ្នា វៃគ្នាតិចវៃគ្នាទៅ ក៏អង្គការសហប្រជាជាតិគេដឹកទៅនៅជំរុំខាវអ៊ីដាងក្នុងរយៈពេលបានជិតម៉ាឆ្នាំ ។ កាលសម័យនឹងបើគេធ្វើតេស្តមេម៉ាយកូនច្រើន បានទៅសហរដ្ឋ ។ តែចៃដន្យពូដែលអ្នកនាំទៅជាយដែននឹង គាត់ស្រឡាញ់សង្សារគាត់ គេចោទថាចាប់ថាអី ក៏រត់មកនៅជំរុំថ្មីដដែល អត់បានទៅ ។ ដល់គេវៃញឹក ទៅនៅជំរុំចំការគរចុងឆ្នាំ៨១ ។ ដល់យួនវៃឆ្ងាយជំរុំទៀតទៅ ក៏យើងមកនៅដីថៃគ្រោះក្រហមទៀត ។ ដល់នេះអង្គការសហប្រជាជាតិគេដឹកយើងមក២ជំរុំ គេហៅជំរុំសាយធូ ហើយនឹងម៉ាឡៃ តើប្រជាជនរូបណាជ្រើសរើសទៅម៉ាឡៃក៏បាន ទៅសម្ផ្ញាញ់ក៏បាន អ្នកណាកាត់ចិត្តទៅណាក៏បាន ។ ក៏ក្រុមគ្រួសារខ្ញុំ ម្ដាយខ្ញុំកាត់ចិត្តតាមព្រះសង្ឃ គាត់ជឿជាក់ថាលោកទៅណាគាត់ទៅនឹង ។ តែមកដល់ស្រុកម៉ាឡៃនេះ ចូលតំបន់ខ្មែរក្រហមដដែល ។ មកដល់ផ្លាក់ខ្ទនក្តុក ។

ធានី ៖ សម្រេចចិត្តតាមលោកសង្ឃ?

ប្អូន ៖ បាទ!

ធានី ៖ ព្រះសង្ឃខាងណាវិញ?

ប្អូន ៖ ព្រះសង្ឃកាលនឹងនៅជំរុំចំការគ ទាំងអស់ម៉ាជំរុំនឹង ដល់ពេលទៅនៅដីថៃ កាកបាទក្រហមគេបែងចែកជា២ យើងទៅសម្ភាញ់ទៅ មកម៉ាឡែមក១ ។

ធានី ៖ ដល់ហើយម៉េចបានសម្រេចចិត្តមកម៉ាឡែ?

ប្អូន ៖ ម្តាយខ្ញុំសម្រេចចិត្តថាលោកទៅណា គាត់ទៅនឹង ឲ្យតែមានព្រះសង្ឃគាត់នេះ ។

ស៊ីថា ៖ គាត់បានធ្វើបុណ្យ ដល់ពេលមកដល់ម៉ាឡៃភ្ញាក់ខ្លួនព្រើត ។

ធានី ៖ អត់មានព្រះសង្ឃទេ មកដល់ម៉ាឡៃ?

ស៊ីថា ៖ ដូចអត់មាន ផ្សឹកអស់ហើយ កាលយើងមកនៅនឹងដូចអត់មានលោក ។

ប្អូន ៖ កាលយើងមកនៅគីឡូ៩ដូចអត់មាន ។ មកនៅម៉ាឡៃកាលឆ្នាំចុង៨២ ដើម៨៣មកនៅបានម៉ាៗរយៈ ។ កាប់ព្រៃនៅសុទ្ធ មូស ឆាប់គេហៅថាគ្រុនចាញ់ សឹងថាឆាប់ខ្វាចភូមិ ។

ស៊ីថា ៖ ម៉ែក៏ធំអាទឹកគេ ហើយខ្ញុំក៏សន្លប់ អត់ឆាប់ ។

ប្អូន ៖ ឆាប់ទាំងអស់អ្នកណាគ្រាន់ជាងគេ អ្នកនឹងហើយដាំបាយហូប តែកាកបាទក្រហមមកជួយជាប់តាមយើងជាប់នៅតំបន់ខ្មែរក្រហមមកជួយបើកអង្ករ ។

ស៊ីថា ៖ ពេទ្យគេជួយថ្នាំពេទ្យមើលរហូត ដូចថាប្រជាជនដឹកមកពីនឹងជួយចិញ្ចឹម ប៉ុន្តែងើបពីគ្រុនចាញ់ងើបពីស្លាប់ប៉ុននឹង រុះសក់អស់ចេញនៅចេះតែនៅអ្នកណាឆាប់ៗទៅ ។

ប្អូន ៖ ហើយនៅដល់បានរយៈពេលម៉ាឆ្នាំ ចុង៨៣ យួនចាប់ផ្តើមវ៉ៃបោសសំអាតទាំងអស់ យួនវ៉ៃបែកទាំងអស់ ទៅនៅជំរុំតាឡុំក សាយអេច ។

ស៊ីថា ៖ ផុតពីជំរុំនឹងទៀតទៅ គេធ្វើមាតុភូមិនិវត្តន៍ អត់មានដីមានអីទេ ដាក់កន្លែងណាអង្គការបើកដីឲ្យមកនៅយាយអ៊ិតនៅអីនឹង គេប៉ាវ៉ា និងខ្មែរក្រហមវ៉ៃគ្នាទៅ ក៏នាំគ្នាមកនៅតាមជាយដែននឹងដដែល ។ តែតឹងម៉ាសារទៀត មុនផ្តាច់ខ្លួននឹងយ៉ាប់ ។

ប្អូន ៖ គិតទៅសម័យនឹងខ្ញុំពេញជំទង់ គេហៅនារសា ម្តាយខ្ញុំលាក់ខ្ញុំនៅក្នុងអូរពីនាក់បងប្រុស ហើយយើងមកនៅឆ្នាំ៨៣ ។

ស៊ីថា ៖ ហើយប៉ុនខ្ញុំអីពេញរូបអីគេឲ្យនៅដឹកជញ្ជូន ខ្មែរក្រហមអត់សម័យប៉ុលពតមែន ប៉ុន្តែតឹង ។ ប៉ុនចេះរស់នៅ គេប្រើឲ្យធ្វើអីយើងចេះទៅ ប៉ុនថារួចរកស៊ីអីខ្លះទៅ ។ ហើយពួកខ្ញុំអ្នកនៅម៉ាឡៃនេះដូចថាអ្នកកើបរកស៊ី គេស្តីគេថាគេចង់ចាប់ដាក់គុកនៅតែលួចទៅដីថៃយកអីវ៉ាន់មកលក់ ។

ប្អូន ៖ ម្តាយខ្ញុំលាក់ខ្ញុំនៅក្នុងអូរ ដល់យើងចូលទៅនៅជំរុំឆ្នាំចុង៨៥ដើម៨៦ ម្តាយខ្ញុំឲ្យខ្ញុំប្អូនៗបងប្រុសខ្ញុំមុនហើយគាត់ចេញទៅនៅថៃ បន្ទាប់មកបងប្រុសខ្ញុំប្អូនយកខ្ញុំទៅនៅថៃ ។ ខ្ញុំទើបចូលឆ្នាំ៩៥នេះនឹង ។

ធានី ៖ អ៊ំនឹកឃើញម៉េចយកកូនទៅលាក់ក្នុងអូរ?

ម្ដាយ ៖ គេចាប់យកធ្វើការ គេឲ្យយកទៅជីកជញ្ជូនគ្រាប់ នៅតូចៗពេក បែកប្ដីបាត់ហើយ អាកូនតូចៗ វាទៅទៀតវាទៅទៀត តូចៗ ។

ធានី ៖ ដល់ពេលបងត្រូវគេប្រើ?

ស៊ីថា ៖ ត្រូវជីកជញ្ជូន ប៉ុន្តែអត់បានទៅជីក ចេះនៅកើបនៅនេះហើយដល់ពេលនេះវាពិបាក ។

ម្ដាយ ៖ អានេះគេយកបងវាមួយនៅក្នុងឃុំនឹង វាមួយគេជីកូចឡានចាប់ យើងអត់ឲ្យចាប់ ឲ្យចូលក្នុងអូរក្នុងអីបាត់ៗទៅ ។

ប្អូន ៖ អូរជាយដែនយើងនឹង ។

ធានី ៖ នៅនឹងរហូត?

ប្អូន ៖ គិតនៅនៅតាំងពីឆ្នាំ៨៣ ។

ធានី ៖ នៅក្នុងអូររហូត?

ស៊ីថា ៖ អត់ទេ ។

ប្អូន ៖ នៅពេលវគ្គ ពេលគេគឹងយើងចូលទៅនៅ ។

ធានី ៖ គេឆូរយើងទៅនៅផ្ទះរបស់យើង?

ប្អូន ៖ បាទ!

ស៊ីថា ៖ ហើយអត់សូវដែលហ៊ាននិយាយអីទេ គេហៅថាដូចថាដាំដើមគរ មិនសូវចេះនិយាយ កុំឲ្យនិយាយអីចឹង ។ យើងសុទ្ធអ្នកពួកប្រជាជន អត់មានធ្វើទាហានធ្វើអីទេ ព្រោះតែកូននៅតូច ចេះនៅតាមគេ ចុះជ្រុលខ្លួនមកនៅរៀងលំបាកហើយចេះថានៅ ដូចថានៅសាយធូសម្ញាញ់ អីគេសេរីស្រួល ។

ប្អូន ៖ តែគ្រាន់បានទៅនៅជុំវិញបានសិក្សា បានអង្គការសហប្រជាជាតិគេបានរៀបចំត្រឹមត្រូវ គេចែកនំប័ង្គឲ្យហូប ។ តែខ្ញុំរៀនមិនបានខ្ពស់ទៅ រៀនបានត្រឹមថ្នាក់ទី៣ មកចូលនៅវគ្គ បងប្រុសខ្ញុំរៀនដល់ថ្នាក់ទី៣ដែរ គ្រាន់បានសិក្សានៅវគ្គបានច្រើន ។

ធានី ៖ ចង់ឲ្យបងនិយាយពេលរត់ពីបាត់ដំបងមក បីប្អូនរហូតដល់ប្អូនស្លាប់?

ស៊ីថា ៖ អានឹង៧៩ ។

ធានី ៖ ចង់ឲ្យបងរៀបរាប់កន្លែងនឹងបន្តិចបានទេ រហូតមក?

ស៊ីថា ៖ ៧៩ ខ្ញុំដូចថាទម្រាំប្អូនស្លាប់ ហើយវាវេទនា ។

ប្អូន ៖ ចេះខ្ញុំនិយាយ ដើរ៤នាក់បងប្អូន ខ្ញុំច្បាស់ៗ ចាំមើលពេលបែកពីម្ដាយយួនបាញ់ទៅ ៤នាក់រត់ទៅតាមៗចាស់ទុំម៉ាសេរីប៉ារបស់ខ្ញុំ ជាកូនពេទ្យរបស់ប៉ាខ្ញុំពីសម័យនឹងដែរ ។ គេឡើងយក

ទៅខែវស្សាទៀត ហើយពេលបងស្រីរបស់ខ្ញុំនឹង គេអាណិតជាងគេ ដេកកន្លែងណាគេមានតង់ គេអ្នកធំ គេឲ្យបងស្រីខ្ញុំនេះដេកក្នុងតង់។ តែចំពោះខ្ញុំ និងបងប្រុសខ្ញុំដេកហាលតែទឹកភ្លៀងម៉ាខែ៣០ថ្ងៃ។

ស៊ីថា ៖ ចុះមានប្អូន ហើយអត់សូវនៅជិតគេទេ ប្អូនដុះអាចម៍វាប្រឡាក់គេដេញ។

ប្អូន ៖ ហើយក្នុងពេលនឹង ប្អូនពៅខ្ញុំដែលបែកអន្ទុយង៉ានឹង គេសុំយកវែវចោលទេ ព្រោះយំពេក កាលណាយំខ្លាំងទៅវាព្រួដល់វៀតណាម។

ស៊ីថា ៖ ខ្ញុំយកក្រមាញ៉ុកមាត់វាទៅ ដល់ពេលនឹងវាស្រែក។

ប្អូន ៖ ចុះវាហេវ វាដាច់ដោះ ព្រោះវា៧ខែ។

ស៊ីថា ៖ ហើយគេសុំអត់ឲ្យ។

ប្អូន ៖ ហើយបងស្រីខ្ញុំអោបអាប្អូនជាប់ដៃនឹង។

ស៊ីថា ៖ ហើយពេលយំខ្លាំងពេកទៅ មូលក្រមាញាត់មាត់វា ដល់ពេលប៉ុនគេឈប់តង់នៅណា យើងឈប់ឆ្ងាយពីគេបន្តិច ចុះប្អូនវាតូចយំ វាឃ្លាន។ ហើយដល់ពេលញាត់ក្រមាមាត់ ហើយដកវិញ។

ធានី ៖ ដកវិញ យំទៀត?

ស៊ីថា ៖ យំទៀត ដល់ពេលឲ្យទឹកវាហូប ឃើញទឹកថ្នាំចត់ម៉េចក៏ដោយ ក៏វាលេបទៅរួចដែរ ធ្លាប់តែធំ ដល់ពេលទៅស៊ិតតូច ចុះវាច្រើនខែ។ ហើយរាគអាចម៍រហូត ដល់ពេលអីចឹងខ្ញុំពិបាក ពេលគេសុំវែចោល មានគេចិត្តល្អថាមិនបាញ់អីទេវែ ដូចថាប៉ាខ្ញុំគាត់ល្អដែរ ថាអាណិតគេទុក។ ហើយប្អូនខ្ញុំ២នាក់នឹង ពេលឈប់កន្លែងណាបោះតង់កន្លែងណា គេប្រើទាំងអស់។ គេប្រើឲ្យបេះបន្លែ គេប្រើឲ្យសែងទឹក ថ្ងទឹកជ្រោះៗ ចេះនាំបងប្អូនសែង។

ប្អូន ៖ បើខ្ញុំដឹង កាលនឹងបន្ទាប់ពីអាពៅតូចនឹងមក ខ្ញុំតូចជាងគេលើនឹង។ ពេលយើងឡើងលើភ្នំ គេឲ្យយើងស្ពាយតីអន្ទរខាងនេះ ខាងនេះមួយជាប់ចង្កេះ ហើយអាក្អមក្តួចៗកំពក់របស់គេ២ចំនិត គេបង្អត់អាបបរលាយស្លឹកឈើម៉ាថ្ងៃ។ ហើយគេហាមបងស្រី និងបងប្រុសទៀត គេហាមថា ២នាក់នេះ បើសិនហៅប្អូនវាស៊ី អញបង្អត់ទាំង២។

ស៊ីថា ៖ បង្អត់ហើយថាទុកនៅលើភ្នំ។

ប្អូន ៖ ហើយដល់នេះ ខ្ញុំឃើញគេហូប ដើរវិលនឹង ដើរធ្មើមុខស្អុយ បងប្រុសខ្ញុំគាត់ហូបរួចនាំខ្ញុំដើរៗ បេះៗស្លឹកខ្ទឹងឲ្យខ្ញុំហូប ហើយៗដើរយូរៗទៅប៉ះខ្យងក្តក់មួយប៉ុននេះដុតឲ្យខ្ញុំហូប ចុះឃើញខ្ញុំអត់នោះ ធ្មើកំពុកក្តួចគេ៣ចំនិត មិនតាំងចិត្តធ្មើកំពុកទេ យើងជំពុកជើង ហើយយើងតូច។

ស៊ីថា : តែប្អូនប្រុសខ្ញុំមុននឹងស្លាប់ វាឃំណាស់គិតពីឃំ ហើយខ្ញុំពិបាក ដល់ពេលដេកកន្លែងដំបូកមួយ នឹងដូចទើបនឹងបែកថ្មីៗដែរ ។ កន្លែងលង់លក់ពេកទៅរមិលចូលឈិតធ្លាក់ជ្រោះ ហើយគេដើរទៅឃើញក្រឡាប់សុទ្ធដីសុទ្ធអី គេស្មានតែខ្មោច ក៏ភ្ញាក់ទៅយកប្អូនមក បើធ្លាក់ចប់បាត់ហើយ ។

ប្អូន : ពេលឡើងលើភ្នំរត់តាមគេនឹង គេអត់ដាស់យើងទេ ។

ស៊ីថា : គេអត់ដាស់ទេ ប្រុងរហូត ។

ប្អូន : ខទាហរណ៍ដេកក្នុងម៉ោយប់នឹង គេអត់ហៅយើងទេ ។

ស៊ីថា : ហើយខ្ញុំចាំអន្ទុយដាស់ហៅប្អូនខ្ញុំរហូត ។

ប្អូន : បើយើងមិនប្រុងប្រយ័ត្នខ្លួនយើង៣នាក់បងប្អូននឹង គេទុកយើងចោលលើភ្នំនឹងម្នាក់ឯង ។

ស៊ីថា : ប៉ុនគេនៅតែថាគេជិតល្អប៉ុននឹង បើសឹងថាគេឥឡូវនៅលើភ្នំ៣នាក់ អញទៅយកអង្ករឲ្យហូប គេទុកចោល ស្លាប់បាត់ហើយ បើភ្នំឡើងដឹងថាភ្នំៗ ។

ប្អូន : តែងាប់ច្រើនណាស់ ហើមប៉ុនៗនេះស្ពាយឆ្នាំង ។

ស៊ីថា : ថាខ្ញុំមុននឹងស្លាប់ប្អូននោះទៅវេទនា ថាដូចថាឡើងខែវស្សារអិលខ្ញុំថាពរប្អូនឡើងមិនរួច ដូរទៅស្ពាយអង្ករគេយកប្អូន ស្ពាយមិនរួចស្រែកឃំ រអិល ។

ប្អូន : ខ្ញុំមុននឹងចុះលើភ្នំនឹង គេដើរចោលហើយ រលឹមអីចឹងដើរអត់ទាន់គេ ។

ស៊ីថា : ដើរទៅខ្ញុំស្តាប់សម្លេងព្រុ ។

ប្អូន : ដើរអត់ទាន់គេ គេឲ្យស្ពាយរបស់ច្រើនពេក ដើរអត់ទាន់គេវារលឹមផង វារអិលផង មិនដឹងគេទៅដល់ណា ដើរបណ្តើរយំបណ្តើរ បានបងស្រីគាត់ស្តាប់ព្រុគាត់ឈប់ចាំ ។

ស៊ីថា : ស្តាប់សម្លេងព្រុសូររំពងព្រៃ ។

ប្អូន : តែបើសិនគាត់អត់ចាំ ខ្ញុំចប់ថ្ងៃដែលគេដើរចោរហើយ ។

ធានី : កាលនឹងបងចាំទេ ដើរតាមអ្នកណាគេ?

ស៊ីថា : ដើរតាមគេហៅពីសម័យនឹងគេហៅគណៈស្រុក គណៈតំបន់ ។

ធានី : ស្គាល់ឈ្មោះគាត់?

ស៊ីថា : គាត់ឈ្មោះអី យឹម ញឹម សារុន ស្គាល់អត់ច្បាស់ រពេចរពិល ប៉ុនគេមានដំរី គេហៅគណៈតំបន់ ។

ធានី : យឹម សារុន?

ស៊ីថា : ឈ្មោះ តា សារុន ហី ។ ពេលដើរជាមួយដំរី ចល់ភ្នំមានតែទឹកនៅឈប់ម៉ោយប់ តែរត់ម៉ោងមួយយប់ៗ ទៅម៉ោង២យប់ ហើយព្រុសូររត់រហូត ដល់ភ្នំរាប់រយភ្នំ ។

ធានី ៖ ដល់ប៉ុន្មានភ្នំ?

ស៊ីថា ៖ មិនដឹងរាប់ភ្នំ ៦ខែសុទ្ធតែភ្នំ ។

ប្អូន ៖ ម៉ាចំនៀរនឹងភ្នំច្រើនណាស់ ស្រុកមោង ជិតដល់កោះកុង ។

ស៊ីថា ៖ ឡើងពីភ្នំបាក់ រហូតទៅដល់កោះកុង ។

ធានី ៖ ម៉េចបានបកមកខាងនេះ?

ស៊ីថា ៖ គេនាំដែលថាគេធ្វើបាបជិតអាក្រក់ ដែលពេទ្យជាមួយប៉ា គេនាំចុះមក ។

ធានី ៖ ស្គាល់ឈ្មោះគាត់ ពេទ្យនៅជាមួយប៉ា?

ស៊ីថា ៖ នៅជាមួយប៉ា ឈ្មោះ ពេទ្យឡោម គាត់ចិត្តល្អថាគាត់ចិត្តល្អ ។

ប្អូន ៖ បើពេទ្យឡោមអត់យកមក ក៏បងប្អូនខ្ញុំចប់ជីវិតនៅនឹងដែរ ។ តែពីអតីតកាលសម័យ៣ឆ្នាំ គេហៅសម័យអំណាចតាប៉ុលពតនឹង គាត់នឹងក៏កូនពេទ្យប៉ារបស់ខ្ញុំ ។

ស៊ីថា ៖ ហើយប៉ារបស់ខ្ញុំនឹង គាត់ពេទ្យនៅចាមរអាលនឹង គេថាក៏អ្នកណាក៏ស្រឡាញ់គាត់ដែរ កាលយើងមិនទាន់៧៩ ។ គាត់បានស្គាល់អ្នកធំៗនៅភ្នំពេញ មុនខ្ញុំទៅលេង ប៉ុន្តែគាត់ចាស់ៗអស់ហើយ ។ កាល៧៩មក គេដូចថាបែកពីបងប្អូនគេនៅកំលោះក្រមុំ ដល់ខ្ញុំវានៅតូចៗគេយកវាពិបាកដូចថាប្អូនមានអី ទាហានភូមិភាគឃើញអន្លុយដក់មាត់ខ្លះគេយំ ឃើញកំសត់ ។ ហើយប្អូននឹងដល់ពេលយូរៗទៅ អត់ទឹកភ្លៀងទៅវារីងថ្កាមស្លាប់ ។

ប្អូន ៖ តែប្អូននឹងស្លាប់បានកប់បានត្រឹមត្រូវដែរ ។

ធានី ៖ មកកប់នៅក្រោមហើយ?

ស៊ីថា ៖ កប់លើភ្នំ ចុះមានវាលមួយ ប៉ុននៅភ្នំទៀត ។

ប្អូន ៖ តែចុះលើភ្នំនឹងមួយហើយមានវាលមួយ ត្រូវការចុះលើភ្នំទៀត ។

ស៊ីថា ៖ ស្លាប់ម៉ោង១១យប់ វារីងថ្កាមពេកអត់មានអីដណ្តប់ ម៉ាចង្កេះខ្ញុំ៥-៦ខែស្ងួតនឹង ស្លៀកនឹងនៅនឹងអត់មានអីផ្លាស់ទាំងអស់ ។ ពេលភ្លៀងយប់ដេកនៅពេលយប់ កាច់មែកឈើប្រឹបៗ ប្អូន ប្រុសខ្ញុំអី ។

ធានី ៖ ដល់ពេលភ្លៀងអីចឹងធ្វើម៉េចទៅ?

ស៊ីថា ៖ ដេកកណ្តាលភ្លៀងទៅ ។

ធានី ៖ មានសត្វមានអី?

ស៊ីថា ៖ ដូចអត់មានអី សមប្រកប ដូចថាអត់មានសត្វអីផង មានតែស្វា មានអីប៉ុន្តែវាអត់ដែលមកធ្វើបាបអីផង ភ្លៀងនៅខ្ញុំនិយាយទៅម៉ារត់៧៩ បើសិនជារឿងយើងបើរត់ពី៧៩រៀបរាប់រឿង

មួយ ប្រហែលជាដាក់រឿងមួយល្អថានៅតូចៗ ចេះនាំគ្នានិយាយអីចឹង ដល់ស្លាប់ប្អូននឹងមួយ ហើយ មកដល់ជួបម្ដាយមានតែខ្លួន ។

ប្អូន : មានប្អូនពៅមួយ សព្វថ្ងៃទំនេរ ។

ស៊ីថា : ដូចបងាចារស្មៀកអានុតខ្មៅពីសម័យប៉ុលពតដើររកតែកូនម៉ាថ្ងៃ ។

ធានី : បានជួបគាត់?

ស៊ីថា : ចាំ! ពេទ្យឡោមនឹង គាត់ដល់ម៉ោងគាត់បកទៅភ្នំម៉ាសារបាននាំចុះក្រោម ។

ប្អូន : នាំចុះមកដល់គេហៅភូមិឫស្សីក្រាំង ។

ស៊ីថា : ភូមិឫស្សីក្រាំង ស្រុកមោងនឹង ។

ប្អូន : មកដល់នឹងគឺហូបបាយផ្អែមហើយ ។

ស៊ីថា : កាច់ពោតឆៅហូបឆ្ងាញ់ ។

ប្អូន : មកដល់ប៉ះបាយហូបឡើងហត់ គេដាក់លើរទេះមិនដឹងផងខ្ញុំប៉ះបាយ ហើយបានផុតពីព្រឹកឡើង គេដាំបាយម៉ាកញ្ចប់៣នាក់បងប្អូនទៅរកម្ដាយដោយខ្លួនឯង ។

ស៊ីថា : រកម្ដាយ ដល់ពេលដើរ៣នាក់បងប្អូននឹង គេវេចបាយឲ្យម៉ាកញ្ចប់នឹងនាំបងប្អូនដើរយប់ជ្រៅ ដូចថាស្គាល់គេ នាំគ្នាពិភាក្សាគ្នា បើស្គាល់គ្នាសុំផ្ទះគេដេក ក៏ដើរទៅម៉ាសារមិនទាន់ជួបទេ មករកម៉ាសារពីឫស្សីក្រាំងមកនោះ អត់ទាន់ជួបអ្នកណា ។ គេមកឃាត់នៅភូមិគេ គេការហូបហត់ អ្នកស្រុកភូមិគេអាណិតពេក គេឲ្យហូបម៉ាថ្ងៃ៣ដង ឲ្យហូបតិច មករកម៉ែតែរកមិនទាន់ឃើញទេ មករកនៅស្រុកមោងនឹង ។ ដល់ពេលចាប់ផ្ដើមមករកទៀតវង្វេងម៉ាសារទៀត គេដឹកទូកទៅភូមិវិញ ។

ប្អូន : បាទ! ព្រឹកឡើងបានគេឲ្យបាយម៉ាកញ្ចប់វេចមក ។

ស៊ីថា : ឲ្យបាយម៉ាកញ្ចប់នាំគ្នាដើរៗដាច់ពីគ្នាឆ្ងាយៗ ។

ប្អូន : ដើរៗដល់ផ្លូវយើង ផ្លូវបែកជា២មិនដឹងជាទៅផ្លូវណាមួយទេ ។ តែបើដូចជាខ្ញុំនិយាយដូចថា អព្ភូតហេតុដែលនាំផ្លូវមិនដឹង នេះអបិយជំនឿ ។ ដើរៗទៅផ្លូវបែកជា២មិនដឹងជាទៅផ្លូវណាមួយ ។

ស៊ីថា : អត់ស្គាល់ស្រុកមោង ។

ប្អូន : បាទ!អត់ស្គាល់ ដល់នេះឃើញអ៊ីមួយ ។

**“ត”**

ប្អូន : ហើយក៏នាំបងប្អូនដើរតាមអ៊ីទូអញ្ជើញបាត់ម៉ាភ្លែត ដើរម៉ាសន្ទុះបានជួបរទេះគេ ។

ស៊ីថា : ជួបគេអុំទូក ។

ប្អូន ៖ ហ្នឹងហើយ ។

ស៊ីថា ៖ យប់ហើយគេអ៊ុំយកមកភូមិនឹងវិញវង្វេងផ្លូវ បានស្អែកឡើងទៅរកទៀត ។ គេឲ្យរកទៀត គេមិនទាន់ឲ្យចេញមកទេ អ្នកស្រុកនឹងគេស្គាល់ប៉ាខ្ញុំដែរ គេស្គាល់ប៉ាខ្ញុំ «កូនពូគេឲ្យសម្រាកទៀតចាំតិចទៀតទៅរកម៉ែ» ។ ខ្ញុំបេះសុំថាបងអើយខ្ញុំសុំទៅរកម៉ែ ខ្ញុំព្រួតែសម្លេងម៉ែខ្ញុំៗនឹកណាស់ ។ គេយកមកទៀត នាំបងប្អូនដើរៗនឹងដាច់ស្រយាល ឆ្ងាយៗពីគ្នា ។ មួយនេះគ្រួន ខ្ញុំកណ្តាលមួយទៀតបន្ទាប់ឆ្ងាយ ។ ដល់ពេលដើរអីចឹងទៅ មានផ្សារគេលក់ គេហៅទិញអីចឹង អត់មានលុយ គេហៅហូបសុទ្ធតែដូរឃ្លានដាច់បាយ អត់មានលុយ ។

ប្អូន ៖ ខ្ញុំដើរមុខគេ អានឹងមកដល់ផ្លូវកៅស៊ូ ។

ស៊ីថា ៖ បានពូម៉ៅគាត់ជួប ។

ប្អូន ៖ ដើរផ្លូវកៅស៊ូបានប៉ះប្អូនខាងម្តាយខ្ញុំឈ្មោះ ម៉ៅ គាត់កំពុងលាងគោនៅគៀនផ្លូវកៅស៊ូ ស្រុកមោង ឃុំព្រៃស្វាយ ភូមិព្រៃស្វាយនឹង ។ គាត់កំពុងលាងគោ ជួបខ្ញុំដើរមុនគេ គាត់ក្រឡេចឃើញឲ្យនាក់គាត់ថានឹងហើយ ។ ចុះគាត់ម្តាយចាត់ទុកហើយ ឲ្យតែកន្លែងណាកូនកំព្រាក៏ម្តាយខ្ញុំដើររកម៉ាផ្លូវគាត់ដើររកម៉ាផ្លូវ ហើយបងប្អូនផ្សេងៗដើររកម៉ាផ្លូវម្នាក់ ។ ហើយគាត់ក្រឡេចឃើញថានឹងហើយ៣នាក់ ៤នាក់អាតូចនោះគាត់មិនសង្ស័មដែរ យូរហើយ ។ ដល់នេះសួរខ្ញុំមុនគេ «ប្អូន ឯងទៅណា?» ថា«ខ្ញុំទៅរកប៉ាខ្ញុំ ម៉ែខ្ញុំ» «ប៉ាឯងឈ្មោះអី» ក៏ប្រាប់ទៅ គាត់ក៏មិនធ្វើឲ្យឃើងអរដែរ ។ «អឺ! បើអីចឹង ឯងដើររកប៉ាឯង ម៉ែឯងផ្ទូតទឹកជាមួយពូសិនចុះ យប់នេះដេកផ្ទះពូ ហូបបាយផ្ទះពូ» ព្រួតែបាយក៏អរ ។ ហើយមិនដឹងទៅរកណាផង ។ ហើយគាត់ឲ្យផ្ទូតទឹកផ្ទូតអីដេកផ្ទះគាត់ ។ ព្រឹកឡើងគាត់ដឹករទេះគោមកដល់ស្រុកមោង ហើយពីព្រៃស្វាយមកស្រុកមោងប្រហែលជា៥ - ៦គីឡូ ។

ម្តាយ ៖ ៨គីឡូ ។

ស៊ីថា ៖ ហើយម៉ែកំពុងស្ទៀកពាក់ដើររកកូនទៀត វេចបាយម៉ាកញ្ចប់ ។

ម្តាយ ៖ ថារកគ្រូមើល ព្រួគេថាកូននឹងចុះមកពីភ្នំហើយ ប្រហែលមកទូងស្គរធំ ហើយនៅស្រុកមោងហើយនឹងស្រុកបវេលនឹងវាឆ្ងាយគ្នាដែរ ។ មកហើយ កូននឹងមកហើយទៅរកទៅឃើញហើយដំណឹងគេថាចុះតាមស្រុកបវេលនឹង វេចបាយបំរុងនឹងទៅ ។

ស៊ីថា ៖ ហើយដល់ជួបម្តាយទៀត គាត់អត់មានបានអី បែកម៉ាភ្លែតបែកជា៣ បែកកូនផ្សេង បែកប្តីគាត់ផ្សេង ។ ដល់ពេលអីចឹង គាត់មានតែខ្លួន ដល់ពេលជួបកូនអីចឹងទៅ គ្មានអីចិញ្ចឹមកូន នាំកូនទៅបូត២នាក់ខ្ញុំមក បូតបានម៉ាកំប៉ុងយកមកបុក ។ ហើយផ្កាស្មោរ ឆាទៅហូបទៅក្អួត អត់មានអីហូបទេ ហើយដល់ពេលអីចឹងពិបាកពេកទៅ ក៏ខ្ញុំមកអូរជ្រៅមុនម៉ែ ។

បូន ៈ អង្ករម៉ាកំប៉ុងនឹងម្តាយខ្ញុំគាត់បបរឲ្យឆ្អិនជាមួយត្រួយល្ពៅ គាត់បបរឲ្យកូនហូបឆ្អែតហើយ បាន គាត់ហូបតាមក្រោយ ។

ស៊ីថា ៈ អត់ម៉ាសារបានកើតមកនៅអូរជ្រៅ ។

បូន ៈ មូលហេតុនឹងហើយបានមកនៅតាមជាយដែន មកដល់ផ្ទះសម្ភាសន៍ ។

ស៊ីថា ៈ ហើយដឹងផ្ទះសម្បែងនៅណានឹង ពីសម័យនឹងចេះអត់ ចេះនាំកូនមក មានឆ្នាំងមួយកូន៤នាក់ ដើរម៉ែកូន ចេះដើរ ។

ធានី ៈ ដើរពីណាទៅណា?

បូន ៈ ដើរពីស្រុកមោង ទៅដល់គេហៅយើងជាប់ព្រំប្រទល់យើង គេហៅនងចាន់ តំបន់៤ តំបន់៥ ចំការ-គនេះ ស្រុកស្វាយចេក ខាងដើងប៉ោយប៉ែតគេហៅចំការគ គេហៅនងចាន់ហួសអូរពា ជាន់ ដើរតាំងពីស្រុកមោង ខេត្តបាត់ដំបង ។

ធានី ៈ ដើរតាមផ្លូវជាតិរហូត?

បូន ៈ អត់ទេ! ពេលដែលដើរចេញពីស្រុកមោងមក យើងដើរតាមផ្លូវកៅស៊ូរហូត មកដល់ស្វាយ នេះគេហៅម៉ាក់ ឬដីឡូត៍ថ្មីកូនខ្លា យើងដើរកាត់ព្រៃ ហើយមានចោរបាញ់ងាប់តាមផ្លូវ ទម្រាំ យើងដល់ជំរុំនងចាន់ មានចោរលួច មានចោរប្លន់ ។

ធានី ៈ ប៉ះទេ?

បូន ៈ តែកាលមកបានតែឮលនឹងគេ អត់ប៉ះទេ ។ ឮលក្រាបថាចោរនាំគ្នារត់ ។

ស៊ីថា ៈ មកដល់ជំរុំភ្លាមអត់មានមុខរបរទៀត កំសត់ម៉ាសារទៀត កាលនៅតូចៗ ។ កំសត់គ្រង់ថា ម្តាយអត់នាំកូនរកស៊ី រែកទឹកលក់ ។

ធានី ៈ នៅជំរុំ?

ស៊ីថា ៈ ចា៎!

ធានី ៈ ក្រែងគេឧបត្ថម្ភហើយ ម៉េចក៏យើងនៅ?

ស៊ីថា ៈ ឧបត្ថម្ភកាលមិនទាន់នៅជំរុំថ្មីមុនដំបូង ដូចមិនទាន់ឧបត្ថម្ភអីផង ។

ម្តាយ ៈ មិនទាន់យកអង្ករមកចែក ហើយបើចែកក៏យើងយកអត់បាន ។

ធានី ៈ ម៉េចអីចឹង?

ស៊ីថា ៈ ចុះម៉េចឈ្នះប្រុសៗ ។ តែម៉ាជំនាន់នឹងមិនទាន់មានបើកអង្ករផង រែកទឹកលក់ ម៉ែរែកទឹក លក់ ។

ម្តាយ ៈ ធ្វើស្បូវលក់ ដល់ពេលគេឈប់ទិញស្បូវទៅ រែកទឹកលក់ហើយ ។

ធានី ៈ មានលុយចាយមានអីហើយ?

ស៊ីថា ៖ មានលុយចាយអីហើយ ចាយលុយថៃ ប៉ុនអង្ករអត់ទាន់ខបត្ដម្ភទេ ទើបជិត១ គេជំនួយដែរ ប៉ុន្ដែមុនដំបូងអត់មានទេ ។

ធានី ៖ ចុះបានអីហូប?

ស៊ីថា ៖ ចុះរកនឹង រែកទឹករែកអីបន្ដិចអង្ករ ។

ធានី ៖ ចុះអ្នកផ្សេង?

ស៊ីថា ៖ អ្នកផ្សេងដូចគ្នា ប៉ុន្ដែដល់ពេលក្រោយមកបានគេដឹកអង្ករយកទៅចែក កាកបាទយកទៅចែកឲ្យ ហើយដណ្ដើមគ្នា ហើយយើងតូច១ មានដណ្ដើរឈ្នះគេណា ។

ធានី ៖ គេមិនមែនចែកតាមគ្រួសារ?

ម្ដាយ ៖ ចែកតាមសម្រួល ប៉ុនអ្នកគេចង់បានបំពានរូសទៅ យើងអ្នកចង់បានដែរ ទារមិនទាន់គេទេ ។

ធានី ៖ បានទទួលអត់?

ម្ដាយ ៖ បាន ជួនណាបាន ជួនណាអត់ ។

ធានី ៖ យកទៅចែកអស់ទៅ យើងថាអត់ទាន់បានគេអត់ឲ្យដែរ?

ម្ដាយ ៖ ចុះបើអស់ពីឡានហើយ បានអីឲ្យគេ ។

ស៊ីថា ៖ បើទឹកចែក១ដណ្ដើមគ្នាវាចែកមិនពេញសិទ្ធិទេ វា១ឡាន២ឡាន៨១០ឡានយើងអត់គ្រប់គ្នា ប្រជាជនរាប់ម៉ឺនរាប់សែនអ្នកបើនៅជំរុំ ដេកនៅដីឡើងត្រៀបអត់មានផ្ទះមានអីទេ កាលមក នៅជំរុំថ្មីកំសត់ម៉ាសារទៀត ។ ហើយពួកខ្ញុំរៀនដល់ខាវអ៊ីដាង ដល់ហើយគាយាយអីត្រឡប់ មកវិញ ស្ដាយ យំ មានចិត្ដនៅតូច១ ចង់ទៅនៅអាមេរិច ។

ម្ដាយ ៖ វាមិនដឹងរឿងថាអាមេរិចអីទេ កាលដែលយើងទៅណា វាដឹងថាទៅក្រៅ១ ដល់ពេល ។

ស៊ីថា ៖ ហើយយន្ដហោះមកយកម៉ាថ្ងៃ១ ដូចថាម៉ាយន្ដហោះបញ្ជូនរហូត អឺអីឡើងពេលនឹង ។ បើខ្ញុំ ទៅ១មុនគាត់ ដល់ពេលនេះគាត់ទៅទាំងអស់ ម៉ាពូជប៉ាខ្ញុំនឹង គាត់ទៅទាំងអស់ តែពួកខ្ញុំមក វិញ ។ មកវិញទាហានថាចេះ ឲ្យទៅនៅប្រទេសគេហើយមិនទៅទៀត ចាំមើលទៅនៅខ្មែរវិញ ឲ្យយួនវ៉ៃវាប់ឆ្អើល ដូចថាថៃគេថាឲ្យមក ។ មកនៅជំរុំនឹងវេទនា គ្មានអីទីពឹង ចេះបានដូចថា នៅជំរុំយួនវ៉ៃអីចឹងទៅខ្វាត់មកនៅដល់ម៉ាឡៃ ថាសម្លឆ្ងាញ់ ស្រុកម៉ាឡៃ អ្នកណាល្អជាងជ្រើស រើសមក ។ ដល់អីចឹងពួកខ្ញុំនាំគ្នាសម្រេចចិត្ដមកនឹង មកទាំងអស់គ្នា ។

ធានី ៖ មកណាដំបូងមក?

ស៊ីថា ៖ នៅអីគេហៅគីឡូ៩ សុទ្ធតែព្រៃ មើលទៅព្រៃក្រែតសុទ្ធយំ មកនៅនឹង ។ ដល់ពេលបារាំង ចិញ្ចឹមទៅនៅជំរុំ ។ ដល់ពេលមកពីជំរុំវិញ ផ្ញើមាតុភូមិគេថាស្មគ្រ័ចិត្ដទៅនៅណា បើអត់មានដី ធ្លី ភូមិស្រុកអត់មានទីពឹង កន្លែងណាបារាំងចិញ្ចឹមគេចែកដីចែកអីឲ្យនៅយាយអ៊ិត ។ ខ្ញុំនឹង

សម្រេចចិត្តប្តីសប្រពន្ធគេសម្លាប់ៗ ថានៅតាមកាកបាទៗចិញ្ចឹមម៉ារយៈពេក ។ ដល់ពេលប៉ាវ៉ា និងខ្មែរក្រហមវៃគ្នា យាយអ៊ិតនឹងធ្វើដុះធ្វើអីរួច ខ្ញុំមកវិញមក ។

ធានី ៖ មកនៅនេះ?

ស៊ីថា ៖ ចាំ! មកនៅនេះកូនចាប់ផ្តើម បើថាយើងតំបន់វៃគ្នាគេស្ងៀយហើយ ។

ធានី ៖ ឆ្នាំប៉ុន្មានត្រឡប់មកម៉ាឡៃវិញ?

ស៊ីថា ៖ មកម៉ាឡៃឆ្នាំ៩៣ ជំនាន់អ៊ុនតាក់ ។

ធានី ៖ ៩៣ បានត្រឡប់មកគេឲ្យលីក្រាប់ លីអីនឹង?

ស៊ីថា ៖ ហ៊ឹ! អានឹងមុន តាំងនៅគីឡូ៩ ប៉ុន្តែជំនាន់អ៊ុនតាក់ខ្ញុំត្រឡប់មកនៅម៉ាឡៃវិញ ។

ធានី ៖ នៅម្តុំណា?

ស៊ីថា ៖ នៅម៉ាឡៃ នៅភូមិដូង កូនចៅអីចេះតែរៀន កាលពេល៧៩មក ។

ធានី ៖ កាលពេល៩៣នឹងមានសាលារៀនហើយ?

ស៊ីថា ៖ មិនទាន់មានស្រួលបួល វាមិនទាន់ច្បាស់លាស់ ដូចថានៅវៃគ្នា ដូចថាម៉ាជំនាន់នឹងតាសុន សេន ដូចតាម៉ុកដូចអីនៅបញ្ញាច្បាំងជាមួយប៉ាវ៉ា ខ្មែរក្រហមនឹងគេថាយើងរកស៊ីអីចឹងថា ពុករលួយ នាយទុន ពួកតាម៉ុកអីនឹង ។ ដល់ពេលគេចាប់ផ្តើមផ្តាច់ខ្លួនបានធូរៗ ទើបធូរជាង១០ឆ្នាំ

ធានី ៖ បងទើបរស់នៅជាប្រជាជនធម្មតា?

ស៊ីថា ៖ ចាំ! ប្រជាជនធម្មតា ។

ធានី ៖ អ្នកណាគេគ្រប់គ្រងពួកបងកាលពេលនៅ៩៣ នៅខាងគីឡូ៩?

ស៊ីថា ៖ នៅគីឡូ៩ ពួកអ្នកគ្រប់គ្រង គេហៅតាសុន សេន តាកន តានួន ជា ។

ធានី ៖ មួយណាធំជាងគេ?

ស៊ីថា ៖ ខ្ញុំស្គាល់តែតាកន នឹង ប៉ុន្តែធំជាងគេ គេថាតាសុន សេន ។

ធានី ៖ ចុះនួន ជា?

ស៊ីថា ៖ នួន ជា បន្ទាប់ខ្ញុំអត់សូវដឹងច្បាស់ដែរ ប៉ុន្តែខ្ញុំនៅក្រោមគេនឹង ប៉ុន្តែខ្ញុំដឹងច្បាស់ជាងគេ ទាហានអាមេរិចកាំងទ័ពកាន់ទាហាន មានតែតាកននឹង តាសុន សេននឹងពីលើតានឹងទៀត ។ បើមកនៅតាមនេះ ខ្ញុំស្គាល់ច្បាស់ជាងគេ តាអៀង សារី លោក សុខ ភាពកាន់មេទ័ព ។

ធានី ៖ តាអៀង សារីកាន់ខាងអីវិញ?

ស៊ីថា ៖ ខ្ញុំអត់ដឹងកាន់ខាងអីផង ប៉ុនចេះស្គាល់គាត់ ពួកខ្ញុំអត់សូវយកចិត្តទុកដាក់ ដូចថារស់នៅជាប្រជាជនចេះនាំគ្នារកស៊ីទៅ ចេះនៅជាមួយគ្នា ដូចថាខាងគាត់ចេះសេរីជាងខាងនោះ ។

ធានី ៖ កាលមុននៅជាមួយតាកននឹងតឹងពេក?

ស៊ីថា ៖ គឺឯកាលពីជាមួយ ដូចថាគឺឯធ្វើអីមិនបានស្រួលដូចនៅកន្លែង ។

ធានី ៖ កាលពេលនៅនោះ គឺឯនឹងមកពីសុន សេន ឬមកពីនួន ជា?

ស៊ីថា ៖ ខ្ញុំអត់ដឹងដែរ ប៉ុនម្ដុំនឹង ពួកគាត់នឹងគេហៅនៅ៣២នឹង មានក្រុមគាត់ទៅដែលកាន់ ។ ដល់ពេលផ្ដាច់ខ្លួននេះ មានតាសុន សេន តាម៉ុក មកប្រជុំរាល់ថ្ងៃ ប្រជុំដូចថាឲ្យចុះចូលខាងគាត់ ដូចថាឲ្យយើងត្រៀម មានកូនធំត្រៀមទៅដឹកជញ្ជូនគ្រាប់នយោបាយរាល់ថ្ងៃ ។

ធានី ៖ មកប្រជុំប្រាប់ប្រជាជន?

ស៊ីថា ៖ ចា៎! ដូចថាមានចេកមានអីឆាប ទុកហាលពោត ដូចថាមិនចង់ពឹងភ្ញៀវក្រៅឲ្យនៅប្រជាជនចេះនយោបាយថាមិនបាច់ទៅពឹងគេអ្នកដទៃ ។

ធានី ៖ តានួន ជា តាសុន សេនអីខស្សាហ៍មកប្រជុំនៅនឹង?

ស៊ីថា ៖ ចា៎! មកប្រជុំ ។

ធានី ៖ ប្រជុំនៅណា?

ស៊ីថា ៖ ប្រជុំគេហៅសារគាំងកន្លែងមន្ទីរក្នុង កន្លែងយាងសម្ដេចតាចុះ ។

ធានី ៖ គាត់ចុះមកពេលណា?

ស៊ីថា ៖ ខ្ញុំអត់ដឹងដែរ ដឹងមកពីណា ប៉ុន្ដែកាលឯងចុះនឹងឆ្នាំប៉ុន្មានខ្ញុំអត់ដឹង ប៉ុនខ្ញុំនៅគីឡូ៩ ។ ប៉ុនដល់នៅអីចឹង កន្លែងគេប្រាប់កន្លែងសារគាំង កន្លែងសម្ដេចយាងមកសម័យនឹង ។

ធានី ៖ គេប្រាប់ថាម៉េចយកឯកសារអី?

ស៊ីថា ៖ អត់ដឹង ។

ធានី ៖ គេទុកដល់រាល់ថ្ងៃ?

ស៊ីថា ៖ ទុកដល់រាល់ថ្ងៃ ពេលមានបុណ្យទានអី ប្រជាជនទៅគោរពកន្លែងបូរមី កន្លែងសម្ដេចយាយសម្ដេចតាដឹងថាយាងមកពីណាផង ។ ប៉ុន្ដែដូចខ្ញុំដឹងតាមក្រោយដែរ ដូចថាមាននារីៗដឹកជញ្ជូននឹងសម្រាប់ធ្វើម្ហូបធ្វើ ហើយតាអៀង សារីគាត់នៅកន្លែងសារគាំងនឹង ចុះអ្នកធំមិននៅកន្លែងនឹងស្គាល់ប៉ុននឹង ។

ធានី ៖ បងស្គាល់តាអៀង សារីមួយ ចុះតាម៉ុកអី នួន ជាអីខស្សាហ៍មកប្រជុំនៅនឹង?

ស៊ីថា ៖ ចា៎! ខ្ញុំស្គាល់គាត់មកប្រជុំអាគេហៅកាលម្ហឹងជិតផ្ដាច់ខ្លួន ។

ធានី ៖ ៩០ប៉ុន្មាន?

ស៊ីថា ៖ ៩៦ ។

ធានី ៖ ៩៣បងមកដល់?

ស៊ីថា ៖ ចា៎! ៩៦ផ្ដាច់ខ្លួន ៩៦ ៩៧ ។

ធានី ៖ ពេលនឹងបានគេប្រាប់?

ស៊ីថា ៖ ឃើញគាត់ គេហៅពួកខ្ញុំទៅប្រជុំ ។

ធានី ៖ និយាយអីខ្លះ?

ស៊ីថា ៖ និយាយដូចថា យើងពាក់មាស ពាក់អីទៅ គេថាពួកដែល១០២ សុទ្ធតែពួកនាយទុកចេះរកស៊ី

ធានី ៖ ស្តីឲ្យ?

ស៊ីថា ៖ ចាំ!

ធានី ៖ តាអៀង សារី ថាម៉េចទៅ គាត់អ្នកគ្រប់គ្រងនៅនឹង?

ស៊ីថា ៖ តាអៀង សារី ខ្ញុំអត់ឃើញផង ឃើញតែតាម៉ុកតាអីមក តានួន ជា តាសុន សេន ។

ធានី ៖ ហើយមកនិយាយអីចឹង?

ស៊ីថា ៖ ចាំ! មកប្រជុំរាល់ថ្ងៃ ទៅដូចថាពួកយើងទៅប្រជុំ គេហៅពួកអ្នកផ្សារ ទៅប្រជុំទៅអីមិនដែលសូវស្តាប់ផង ។

ធានី ៖ គេធ្លាប់មានប្រកាសយកទ្រព្យសម្បត្តិឯកជនរួមទេ?

ស៊ីថា ៖ រួមតើ កាលមិនទាន់ផ្តាច់ខ្លួន រឿងអ្នកលក់ដូរ ដូចថាយើងលក់១-២កញ្ច្រែងចាប់យកឲ្យកងទ័ពហូប ហើយពេលដែលថាផ្ទះខ្ញុំលក់ចាប់ហួយតម្លៃ១០-២០ម៉ឺនបាតអីក៏ដោយ ទយគូថឡានចាប់ឲ្យទាហានហូប ។ ហើយឡានអីយកដាក់រួមទាំងអស់ ហើយយកឡានប្រើ យើងទិញតម្លៃប៉ុន្មានក៏បានដែលថ្មីៗមុនផ្តាច់ខ្លួននឹង ។

ធានី ៖ ម៉េចទៅ?

ស៊ីថា ៖ ដល់ពេលអ្នកម្ចាស់ដែលទិញឡានទិញអីរីងរៃដោយសារ ប៉ុនមិនដឹងធ្វើម៉េច ។

ធានី ៖ បងអីចឹងដែរ?

ស៊ីថា ៖ ខ្ញុំអត់បានទិញផង ម៉ាជិនាន់នឹង ។

ធានី ៖ បងប្រមូលរួមលក់ដូរ?

ស៊ីថា ៖ លក់ដូរគេចាប់ ដូចថាយើងលក់ សាច់ជ្រូក៤-១០-២០គីឡូ លួចលក់ កើបលក់ដាក់ក្នុងផ្ទះលក់ បើគេដឹកគេចាប់ឈ្លោះគ្នា ចាប់យកជញ្ជីងអី បើអត់បានសាច់គេជញ្ជីងទៅ ។ លក់អីក៏អត់បាន គេថាលក់អីចឹងឲ្យខ្នាំងហូប គ្មានម្ចាងម្នាក់ ។

ធានី ៖ បានអីហូប បើចាប់ម្ល៉ឹងៗ?

ស៊ីថា ៖ បាន គេមានពាណិជ្ជគេ ពាណិជ្ជរួម ដូចខ្ញុំចង់ទិញត្រី១០គីឡូ លូកដៃទៅគេធ្វើប្រឡោះមួយធំយើងទិញ១០-២០គីឡូ គេថ្លឹងនៅក្នុងបន្ទប់គេៗធ្វើដាក់ប្រស្សីបន្ទប់ គេមានពាណិជ្ជរួម ។ រួម

នឹងសម្រាប់ថា ដូចថាក្រុមហ៊ុនគ្នា១០០ ឬ៥០នាក់ សម្រាប់បានលុយផ្តល់កងទ័ពជួយ ។ យើងរកស៊ីឯកជនគេចាប់ ។

ធានី : បើបងទិញពីគេយកមកលក់ម៉េច មិនថ្លៃ?

ស៊ីថា : អត់ទិញពីគេផង លើកអត់បាន បើចង់លើកលក់អត់បានផង គេឲ្យមានអាពាណិជ្ជនឹងម៉ាកន្លែង

ធានី : យើងទៅទិញយកមកញ៉ាំខ្លួនឯង?

ស៊ីថា : ចា៎! បានតែទិញយកមកញ៉ាំ ប៉ុន្តែបើយើងចង់លក់អត់បាន ។

ធានី : ចុះយើងបានលុយពីណាទិញ បើយើងអត់មានធ្វើអីផង?

ស៊ីថា : កាលម្ហូងនឹងចេះនាំគ្នារកស៊ី មិនដឹងធ្វើអីបាន ។ ដាំពោតដាំអីលក់ឲ្យថៃ ។

ធានី : គេឲ្យលក់?

ស៊ីថា : ចា៎! ប៉ុន្តែគេអត់មានឲ្យទិញលក់ទេ ។ ពួកខ្ញុំរឹងចចេះ ដូចថាទៅលួនទៅក្រាបទៅដីថៃ ទៅរែកត្រី រែកអីយកមកលក់ ពេលទៅតម្រួតគេបើកឡានដើរចាប់យកទាំងឡានៗ ដូចថាមានស្អីលើយកទាំងអស់ ខ្លះគេអាណិតគេមកប្រាប់ ។ ផ្ទះខ្ញុំលក់ស្រាបៀរ លក់ចាប់ហួយ គេប្រាប់ស្រាលាក់ក្នុងស្រះទឹក លាក់ក្នុងទឹកក្នុងភក់ ទាហានប៉ូលីសគេៗស្គាល់ខ្ញុំ ។ គេថា«គេប្រជុំថ្ងៃមុនគេរកចាប់នាងឯងហើយ ថាចចេះ ពូកែលក់អីចឹងគេឲ្យមកចាប់ហើយ ។ យប់ឡើងគេមកប្រាប់យើងលាក់ពីយប់ ។ ដល់ពេលគេមកឆែកមើលអត់មានអីទេ មានតែម៉ាស៊ីនទឹកកកចេះលាក់ ។ ថ្ងៃមុនផ្តាច់ខ្លួនពិបាក ។

ធានី : បងថាមានមីនមានអី?

ស៊ីថា : មានកន្លែងគេ កន្លែងម៉ក់ហឹន ។

ធានី : តែកន្លែងម្តុំផ្ទះបងរកស៊ីអត់មាន?

ម្តាយ : រាវៗអស់ហើយ គេចេះរាវ ។

ស៊ីថា : គេរាវព្រៃគេកាប់ គេអីប៉ុនខ្ញុំនៅអីចឹង រាងស្រឡះហើយ ។

ធានី : ដីនឹងយើងអាចយកបានដែរ?

ស៊ីថា : យកអត់បានទេ ប៉ុនយើងទិញទេ ។

ធានី : បានលុយពីណាទិញ?

ស៊ីថា : បានលុយរកស៊ី ខ្ញុំរក ។

ធានី : នៅពេលជំរុំនឹង?

ស៊ីថា : មកនៅមុនដំបូងនឹង ខ្ញុំមកនៅក៏ទិញគេ ប៉ុនកាលទិញកាលនឹងរៀងធូរថ្លៃដែរ ។

ធានី : ទិញដីនេះ?

ស៊ីថា ៖ ចាំ! ពីមុននោះនៅជិតផ្សារ ដល់ពេលធ្វើពោត សណ្តែកខាតទៅ លក់កន្ទែងនឹងមកវិញនៅនេះនៅគៀនផ្សារ នៅកន្ទែងជិតវត្តធំមូល ។ ដល់សព្វថ្ងៃមិនទាន់មានធូរធារដែរ កូនរៀននៅភ្នំពេញអី ។ ចប់មួយ ទៅ២ទៀតពនាក់ទាំងអស់ រៀនបរិញ្ញាខាងទេសចរណ៍ ចប់ខែ៨ឆ្នាំនេះ ដល់ពេលប្រឡងបាក់ឌុបដាប់២ទៀត ។

ធានី ៖ ទៅរៀនទៀត?

ស៊ីថា ៖ ទៅរៀនទៀត មួយនោះឲ្យរៀនគ្រូពោរគេ ។ ហើយធ្វើចំការអីតិចតួច រកស៊ីដឹកទំនិញមកពីថៃ ។

ធានី ៖ លក់អីខ្លះ?

ស៊ីថា ៖ ទូ ពូក ។

ធានី ៖ លែងរកស៊ីរបស់របរហូបចុក?

ស៊ីថា ៖ ផ្អាករកហើយ មានមុខរបរដឹកទូដឹកពូករៀងគ្រាន់ រកអានឹងវិញ ។

ធានី ៖ ដឹកពីណាទៅណា?

ស៊ីថា ៖ ខ្ញុំចេញពី កាលមុនដឹកពីម៉ាឡៃទៅសៀមរាប ។ សព្វថ្ងៃខ្ញុំចេញនៅច្រកអន្លង់វែក ។

ធានី ៖ ម៉េចបងមកដល់នេះវិញ?

ស៊ីថា ៖ ពេលខ្ញុំសម្រាកខ្ញុំមកដល់ផ្ទះ ។

ធានី ៖ ពេលណាបានធ្វើ?

ស៊ីថា ៖ ២-៣ថ្ងៃទៀត ចេញទៅច្រកសៀមរាប ទៅចេញអីវ៉ាន់ទៅអន្លង់វែង ។ នាំគ្នាបងប្អូនរកទៅ ។

ធានី ៖ លក់ទូយ៉ាងម៉េច?

ស៊ីថា ៖ ទូថៃ ។

ធានី ៖ រកស៊ីយូរឬនៅតាំងបងមកដល់ម៉ាឡៃ?

ស៊ីថា ៖ រកស៊ីខាតចំណេញ វារកស៊ីមិននឹង ។

ធានី ៖ ប៉ុន្មានឆ្នាំរកស៊ីដឹកពូក?

ស៊ីថា ៖ រកស៊ីដឹកទូ ដឹកពូ ៧-៨ឆ្នាំ ។

ធានី ៖ ចិត្តរបស់បងផ្ទាល់ តាំងពីមុនរហូតមកដល់ឥឡូវ បងគិតថារបបមួយណា ឬការរស់នៅកាលពីមុនឥឡូវមួយណាស្រួលជាង?

ស៊ីថា ៖ ឥឡូវស្រួលគេអត់គៀបសង្កត់ បើពីមុនគេគៀបសង្កត់ យើងរកអីអត់បានពេលរកអីចឹង ដល់លួចលាក់បិទបន្ទប់លក់ពីមុន ដល់ពេលសព្វថ្ងៃវារកពេញទំហឹង ថាមុខរបរកុំឲ្យយើងរករបរណា

គេហាមឃាត់ បើគេមិនហាមឃាត់ យើងរកបរដូចថាដឹកទូ ដឹកពូក ធ្វើចំការធម្មតាល្អបានកូនរៀនៗ យើងចេះទំរកទៅវាស្រួលជាងមុនឆ្ងាយ មានសេរីភាព ។

ធានី ៖ បងមានអីចង់សួរ ឬចង់បន្ថែមអីដែលខ្ញុំអត់បានសួរ?

ស៊ីថា ៖ អត់ចង់មានចំងល់អីផង តើចុះផ្សាយដាក់សែតដាក់អីដែរ?

ធានី ៖ ពួកខ្ញុំសរសេរជាសៀវភៅ ។

ស៊ីថា ៖ កាលមុនខ្ញុំចង់ចេះ ខ្ញុំចង់ថាពួកខ្ញុំបើសិនជាតែងរឿងមួយធ្វើរឿងអីកំសត់តាំងពីដើមកត់ ពេលឱកាសល្អជុំគ្នា ។

ធានី ៖ ពួខ្ញុំមានទស្សនាវដ្តីមួយ ហៅថាទស្សនាវដ្ដីស្វែងរកការពិត បើសិនជាបងអនុញ្ញាតិឲ្យពួកខ្ញុំសរសេររឿងដែលបានប្រាប់ខ្ញុំ សរសេរចុះទស្សនាវដ្តីបាន ។ ហើយទស្សនាវដ្តីនឹងល្បីណារបៀបថានិយាយពីប្រវត្តិសម័យខ្មែរក្រហមមក ទូទាំងប្រទេសសាលាស្រុកសាលាខេត្ត ។

ស៊ីថា ៖ បើសិនជាខ្ញុំនិយាយថា ប្អូនប្រុសខ្ញុំពៅនឹង គេចង់សម្លាប់ម៉ាគ្រួសារខ្ញុំម៉ាក្រោមដើមជ្រៃនឹងហើយ តែខ្ញុំសុំអង្វរគេកុំសម្លាប់ខ្ញុំអីទុកឲ្យខ្ញុំរស់ទៅ ពេលប្អូនខ្ញុំយំខ្ញុំញ៉ុកមាត់ កន្លែងមូលក្រមានឹង ខ្ញុំកំសត់កន្លែងនឹង ខ្ញុំខ្លួនឯងក៏យំ ប្អូនក៏ កូនក្មេង ។ ហើយញ៉ុកវាអីចឹង តែមិនញ៉ុកឲ្យខ្លាំងវាថប់ហើយ ពេលយើងញ៉ុកតិចអន់សំលេង ។ ហើយចេះពិបាកចិត្តថាដឹងយំធ្វើអីទេ បងដឹងរស់អត់ទេ បើយំដល់ថ្នាក់នឹង ។

ធានី ៖ បងចាំឈ្មោះ អ្នកណាចង់សម្លាប់?

ស៊ីថា ៖ គេក្រុមគេ ខ្ញុំភ្លេចអស់ហើយ ។

ធានី ៖ គាត់មកពីណាពីណែ?

ស៊ីថា ៖ ពេទ្យក្រុមនារីយោធារត់តាមគេ ដែលក្រុមនៅជាមួយប៉ុន្តែខ្ញុំមានអ្នកចិត្តល្អ មានអ្នកចិត្តអាក្រក់ដល់ពេលនឹងម្នាក់នឹងថាសម្លាប់អី តិចជូនជួបម៉ែឪវា ធ្វើម៉េចកូនពូល្អៗដូចថាប្ដីប្រពន្ធគាត់ល្អ ។

ធានី ៖ ចាំឈ្មោះគាត់ ពូនឹង ពូដែលជួយនិយាយឲ្យបង?

ស៊ីថា ៖ ស្រីទេដែលនិយាយនោះ ។

ធានី ៖ ស្រីនឹង?

ស៊ីថា ៖ ខ្ញុំអត់ចាំទេ ។

ធានី ៖ តែគាត់អ្នកធ្វើការជាមួយ?

ស៊ីថា ៖ ចា៎!ដែលនៅជាមួយ ហើយពេលប្អូនខ្ញុំឈប់កន្លែងណា ខ្ញុំអត់ប្រើគេអត់ឲ្យទាស់ចិត្តទេ ថាប្អូនឯងទៅសែងទឹក ហើយអាមួយបន្ទាប់ខ្ញុំយប់ឡើងលូនលួចអីគេហូប ដូចទឹកស៊ុបគេស្ងោរ ចុះចាស់ៗគេមានទឹកសាច់ស្ងោរដាក់ឆ្នាំង ។ រស់បានអានឹងលូនទៅហូប ។

ធានី ៖ ប្អូននឹង?

ស៊ីថា ៖ ហ្នឹងហើយមួយបន្ទប់នៅភ្នំរាល់ថ្ងៃ។ លួនបបួលអាប្អូនៗតែវាមិនចេះលួចៗទៅបានហូបឆ្អែតចេញមកវិញ។ គេធំៗគេរកបានហូប ហើយដល់ពេលពួកខ្ញុំតូចៗគេអត់សូវខ្វល់ អត់បាយអត់ទៅ។ ជួនកាលគេឲ្យប្អូនខ្ញុំហូបទៅ ខ្ញុំអត់៣-៤ថ្ងៃ អត់ហូបទឹក។

ធានី ៖ បានទឹកពីណា?

ស៊ីថា ៖ ទឹក កាលខែប្រាំងអត់ទឹកទេ កាប់អាវល្វិ៍បន្តក់តាមមាត់តាមអីឲ្យប្អូនហូប ក្រទឹកណាស់ ស្វែងរកតែទឹកឡើងភ្នំនឹង ដល់ពេលខែវស្សាសំបូរទឹកណាស់។

ធានី ៖ ប៉ុន្តែរស់?

ស៊ីថា ៖ ចុះបើសើមទាំងយប់ទាំងថ្ងៃ បើ៦ខែនឹងមានម៉ោចង្កេះនឹង ហើយប្អូននឹងស្រាត។

ធានី ៖ ស្រាតទាំងអស់?

ស៊ីថា ៖ ចា៎! អត់មានខោអាវស្លៀកពាក់ទេ ហើយមានតែភួយមួយរុំ។

ធានី ៖ ប្អូនពៅបង?

ស៊ីថា ៖ ចា៎! រុំដល់តូច ដល់ស្លាប់ទៅក្របភួយនឹងឲ្យ ស្លាប់ទៅយូរតែដៃមួយក៏រួច បិទភ្នែកមិនជិតបិទមាត់មិនជិត តូចដូចស្វាយំអត់ពូទាំងអស់ វាតូច វាស្គមចុះ៨ខែទើបដុះធ្មេញ។

ធានី ៖ ហើយក្តៅខ្លួនក្តៅអី?

ស៊ីថា ៖ អត់ដឹងក្តៅអីទេ មិនដឹងប្អូនយ៉ាងម៉េចបើពរនៅចង្កេះ វាភាគប្រឡាក់ពេញតែខ្លួន ព្រួថាគេឈប់ណា ខ្ញុំទៅដល់នោះ អត់ហ៊ានទៅជិតគេ។ ដល់ពេលអីចឹងវាពិបាកគ្រាន់នឹកឃើញថាបើបានតែងរឿងមួយ ដូចថាមានឱកាសនឹកឃើញរឿងពីអតីត អត់ភ្លេចទេរឿងឡើងភ្នំចុះភ្នំ។

ធានី ៖ បងចេះអក្សរ?

ស៊ីថា ៖ អត់ចេះ។ ហើយម៉ាជីនាន់នឹង ម៉ែខ្ញុំប៉ាខ្ញុំគាត់ជួយលោកតាគង់ សំអុល បងគាត់ ប៉ាខ្ញុំជួយកាលពីសម័យប៉ុលពតនឹង ឲ្យលោកយាយធំនឹងបងតាគង់ សំអុលនឹងនៅដេរនៅកន្លែងមន្ទីរពេទ្យនឹង។ ខ្ញុំទៅម្តង តែឥឡូវគាត់ចាស់ហើយ លោកគង់ សំអុលម៉ែអត់បានជួប កាលនឹងទៅលេង។

ធានី ៖ រាល់ថ្ងៃគាត់ធ្វើការរវាំង?

ស៊ីថា ៖ ចា៎! តែកាលនឹងទៅជួបបងគាត់ គង់ ចាន់ថា។

ធានី ៖ ជួយអីគេ?

ស៊ីថា ៖ ជួយពីសម័យនឹងដូចថាឲ្យគាត់នៅដេរកន្លែងស្រួលលោកយាយ។

ធានី ៖ បងគាត់ស្រី?

ស៊ីថា ៖ ស្រី ឈ្មោះគង់ ចាន់ថា ។

ធានី ៖ ឪពុកបងជួយគាត់យ៉ាងម៉េច?

ស៊ីថា ៖ ជួយដូចថាគាត់ថ្ងៃមុនទៅគាត់ថា ប្រាប់ខ្ញុំៗនៅតូចៗដែរ កាលពីសម័យនឹងយាយបានប៉ាឯង ជួយយាយនៅកន្លែងដេរស្រួល ព្រោះកុំអីយាយទៅជាស្អី ។

ធានី ៖ គាត់ធ្លាប់ទៅលេងភ្នំពេញពេលក្រោយ៧៩?

ស៊ីថា ៖ ទៅលេងដែរ ប៉ុន្តែយាយគាត់ឈឺចាស់ គេនាំចូលទៅកន្លែងនឹង គេយាម ។

ធានី ៖ គេទៅរកបងដល់ផ្ទះ?

ស៊ីថា ៖ អត់រកទេ ខ្ញុំទៅលេងជាមួយម៉ែ ។ ប៉ុន្តែគាត់បានត្រឹមតែរៀបរាប់ប្រាប់ ប៉ុនគាត់ចិត្តអត់សូវ បានទៅលេង ។ ពីសម័យនឹងគាត់នៅនឹងទាំងអស់ម៉ាបងប្អូនគាត់ នៅបាត់ដំបង តែនៅស្រុក មោង ចាមរអាល ។ ទៅលេងម្តង ២ដង ខ្ញុំចូលទៅជាមួយពៅម្តង និង ម៉ែទៅលេងម្តង ។ តែគាត់ចាស់ៗហើយ ឈឺលើសឈាមលើសអី លើកដាក់សុទ្ធតែដុកទ័រ ។

ធានី ៖ មានអីបន្ថែមទៀត?

ស៊ីថា ៖ អត់មានអីផង ។

«ចប់»